JANUARY 2025

City of Long Beach

ការណែនាំអំពីធនធានក្រោមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act)

CITY OF LONG BEACH

CITY OF LONG BEACH

City of Long Beach
ការណែនាំអំពីធនធានក្រោមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act)

ការប្តេជ្ញាចិត្តចំពោះសហគមន៍ជនអន្តោប្រវេសន៍

ទីក្រុងឡុងប៊ិចមានមោទនភាពក្នុងការជួយដល់សហគមន៍ជនអន្តោប្រវេសន៍ដែលមានលក្ខណៈចម្រុះ និងរស់រវើករបស់ខ្លួន។ នៅឆ្នាំ 2018 ទីក្រុងបានអនុម័តច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act) ដែលជួយការពារជនអន្តោប្រវេសន៍តាមរយៈការកំណត់គោលការណ៍ណែនាំច្បាស់លាស់ ដើម្បីចាត់ចែងព័ត៌មានផ្ទាល់ខ្លួន និងបញ្ឈៀសការសហការជាមួយមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍សហព័ន្ធ។ ទីក្រុងក៏បានបង្កើតមូលនិធិយុត្តិធម៌នៃទីក្រុងឡុងប៊ិច (Long Beach Justice Fund) នៅឆ្នាំ 2019 ផងដែរ ដើម្បីផ្តល់ជំនួយផ្លូវច្បាប់សម្រាប់ការពារការនិរទេស។

នៅថ្ងៃទី 7 ខែមករា ឆ្នាំ 2025 ក្រុមប្រឹក្សានៃទីក្រុងបានបោះឆ្នោតដើម្បីពង្រឹងច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច ដោយផ្តល់អនុសាសន៍ថា ការិយាល័យឯករាជ្យនីមួយៗ និងទីភ្នាក់ងារជាដៃគូពីខាងក្រៅជាច្រើនត្រូវប្តេជ្ញាអនុវត្តតាមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច ដោយស្នើឱ្យរួមបញ្ចូលគោលការណ៍ណែនាំស្តីពីឯកជនភាពទិន្នន័យរបស់ទីក្រុងជាភាសានៃកិច្ចសន្យាស្តង់ដា អនុញ្ញាតការផ្តល់ថវិកាបន្ថែមដល់ជំនួយសម្រាប់ការពារការនិរទេស ព្រមទាំងបង្កើត និងចែកចាយឯកសារព័ត៌មានដើម្បីជួយដល់អ្នកដែលត្រូវការជំនួយ។

ការណែនាំនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ធនធានដ៏មានប្រយោជន៍ដល់សមាជិកសហគមន៍ ដែលអាចនឹងត្រូវការជំនួយសម្រាប់បញ្ហាពាក់ព័ន្ធនឹងអន្តោប្រវេសន៍។ ចំណុចសំខាន់គឺត្រូវដឹងអំពីសិទ្ធិរបស់អ្នក និងត្រៀមខ្លួនរួចរាល់ប្រសិនបើអ្នកត្រូវបានឃាត់ខ្លួន ឬសួរសំណួរដោយភ្នាក់ងារអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ និងគយ (Immigration and Customs Enforcement, ICE)។ ដើម្បីស្វែងយល់បន្ថែមអំពីច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច និងសកម្មភាពថ្មីៗនេះរបស់ក្រុមប្រឹក្សានៃទីក្រុង សូមមើលកំណត់ហេតុនេះ។**memorandum**.

ការមិនសហការជាមួយមន្ត្រីអនុវត្តន៍ច្បាប់អន្តោប្រវេសន៍

នាយកដ្ឋានប៉ូលិសនៃទីក្រុងឡុងប៊ិច (Long Beach Police Department, LBPD) មិនមែនជាផ្នែកមួយនៃអាជ្ញាធរអន្តោប្រវេសន៍ និងមិនបំពេញភារកិច្ចផ្នែកអន្តោប្រវេសន៍ទេ។ LBPD ប្តេជ្ញាធានាសុវត្ថិភាពសហគមន៍ទាំងមូលរបស់យើង។ មូលដ្ឋានគ្រឹះនៃនាយកដ្ឋាននេះគឺឈរលើគោលការណ៍អនុវត្តន៍ច្បាប់សហគមន៍ ដែលផ្តោតខ្លាំងលើសារៈសំខាន់នៃទំនុកចិត្តពីសាធារណជន រួមទាំងទំនុកចិត្តពីសហគមន៍ជនអន្តោប្រវេសន៍របស់យើងផងដែរ។ ជាទូទៅ គោលការណ៍របស់ LBPD ហាមឃាត់ការចែករំលែកព័ត៌មានទាក់ទងនឹងអន្តោប្រវេសន៍ជាមួយភ្នាក់ងារអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ និងគយ (ICE) ដែលបានទទួលពីបុគ្គលដែលបានជួបក្នុងអំឡុងពេលធ្វើសកម្មភាពអនុវត្តន៍ច្បាប់ ឬរក្សាសុវត្ថិភាពសាធារណៈ ដូចជាការបញ្ឈប់ចរាចរណ៍តាមទម្លាប់ ហៅទូរសព្ទទៅសេវាកម្ម និងបុគ្គលជាប់ឃុំ។ នាយកដ្ឋាននេះចែករំលែកព័ត៌មាននេះ ដើម្បីអនុលោមតាមច្បាប់រដ្ឋ ឬសហព័ន្ធ ឬតាមដីកាកោះហៅ ឬដីកាតុលាការដែលមានសុពលភាពប៉ុណ្ណោះ។ យើងលើកទឹកចិត្តឱ្យអ្នករក្សាទំនាក់ទំនងជាមួយ LBPD ក្នុងតំបន់របស់អ្នក ដើម្បីជួយជំរុញឱ្យមានសុវត្ថិភាព និងសន្តិសុខសម្រាប់អ្នកគ្រប់គ្នាក្នុងសហគមន៍របស់យើង។

CITY OF LONG BEACH

City of Long Beach
ការណែនាំអំពីធនធានក្រោមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act)

ជំនួយផ្លូវច្បាប់

“ដើម្បីដោះស្រាយភាពយឺតយ៉ាវ ក្នុងការផ្តល់សេវាការពារក្តីករណីត្រូវចាប់បញ្ជូនទៅប្រទេសដើមវិញ សាលាក្រុងកំពុងបំពេញកិច្ចការយ៉ាងសកម្ម ក្នុងការស្វែងរកដៃគូផ្តល់សេវផ្នែកច្បាប់ថ្មី ដើម្បីជួយដល់គម្រោងមូលនិធិយុត្តិធម៌ឡុងប៊ិច។ ក្នុងពេលអន្តរកាលនេះ អ្នកគ្រប់គ្រងក្រុងបានឯកភាពគោលនយោបាយអនុគ្រោះចំនួនពីរ ដើម្បីបង្កើតកិច្ចព្រមព្រៀងបណ្តោះអាសន្ន ជាមួយមហាវិទ្យាល័យច្បាប់ Western State និងគម្រោងសិទ្ធិជនអន្តោប្រវេសន៍ Esperanza។ ដៃគូផ្តល់សេវាទាំងពីរនេះបានប្តេជ្ញាថាចាប់ផ្តើមផ្តល់សេវាការពារផ្នែកច្បាប់ សម្រាប់ជនអន្តោប្រវេសន៍ទាំងឡាយណា ដែលឋិតក្នុងដំណាក់កាលចាប់បញ្ជូន ដោយចាប់ផ្តើមនៅខែ មីនា ឆ្នាំ ២០២៥។ សេវានេះបន្តរហូតដល់ខែ តុលា ឆ្នាំ ២០២៥”។

ធនធានផ្នែកអន្តោប្រវេសន៍នៃទីក្រុងឡុងប៊ិច

ស្ថាប័នផ្តល់សេវាមូលនិធិយុត្តិធម៌នៃទីក្រុងឡុងប៊ិច

ស្ថាប័នភ្ជាប់សហគមន៍

ÓRALE
www.orale.org

Filipino Migrant Center
www.filipinomigrantcenter.org

United Cambodian Community
www.ucclb.org

ស្ថាប័នផ្តល់សេវាផ្លូវច្បាប់

Western State College of Law
www.wsulaw.edu

Esperanza
www.esperanza-la.org

CITY OF LONG BEACH

City of Long Beach
ការណែនាំអំពីធនធានក្រោមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act)

ដឹងអំពីសិទ្ធិរបស់អ្នក

សិទ្ធិរក្សាភាពស្ងៀមស្ងាត់- អ្នកមិនចាំបាច់ជជែកអំពីស្ថានភាពអន្តោប្រវេសន៍ ឬ សញ្ជាតិរបស់អ្នកជាមួយប៉ូលិស ភ្នាក់ងារអន្តោប្រវេសន៍ ឬមន្ត្រីផ្សេងទៀតទេ។ គ្រប់ ពាក្យដែលអ្នកនិយាយអាចត្រូវបានប្រើដើម្បីដាក់បន្ទុកលើអ្នកក្នុងតុលាការអន្តោ ប្រវេសន៍។ កុំកុហកអំពីស្ថានភាពរបស់អ្នក ឬផ្តល់ឯកសារក្លែងក្លាយ។

ឯកសារអន្តោប្រវេសន៍- ប្រសិនបើអ្នកមិនមែនជាពលរដ្ឋអាមេរិក ហើយភ្នាក់ងារអន្តោ ប្រវេសន៍ស្នើសុំឯកសាររបស់អ្នក អ្នកត្រូវតែបង្ហាញភ្នាក់ងារនោះ បើអ្នកមានឯកសារ នៅជាប់ខ្លួន។ អ្នកមានសិទ្ធិរក្សាភាពស្ងៀមស្ងាត់ ឬស្នើសុំនិយាយជាមួយមេធាវី មុន នឹងឆ្លើយសំណួរណាមួយ។

សិទ្ធិចំពោះការឆែកឆេរ -ប្រសិនបើភ្នាក់ងារអន្តោប្រវេសន៍សួរថាគាត់អាចឆែកឆេរខ្លួន អ្នកបានឬអត់ អ្នកមានសិទ្ធិឆ្លើយថា "ទេ"។ ភ្នាក់ងារមិនមានសិទ្ធិឆែកឆេរខ្លួនអ្នក ឬ ទ្រព្យសម្បត្តិរបស់អ្នកដោយគ្មានការយល់ព្រមពីអ្នក ឬគ្មានមូលហេតុសមស្របនោះ ទេ។ ប្រសិនបើគាត់ស្នើសុំឆែកឆេរខ្លួនអ្នក អ្នកមានសិទ្ធិឆ្លើយថា "ទេ"។

ដីកាឆែកឆេរ និងចាប់ខ្លួន -ប្រសិនបើភ្នាក់ងារអន្តោប្រវេសន៍ចូលផ្ទះរបស់អ្នក ដោយគ្មានការអនុញ្ញាតពីអ្នក អ្នកមានសិទ្ធិនិយាយប្រាប់ច្បាស់ៗថា អ្នកមិន អនុញ្ញាតឱ្យគាត់ចូលផ្ទះរបស់អ្នក ឬឆែកឆេរទ្រព្យសម្បត្តិរបស់អ្នកទេ។ ត្រូវ សួររកដីកាឆែកឆេរ និងចាប់ខ្លួន។

ដីកាឆែកឆេរ និងចាប់ខ្លួន -ប្រសិនបើភ្នាក់ងារអន្តោប្រវេសន៍ចូលផ្ទះរបស់អ្នក ដោយគ្មានការអនុញ្ញាតពីអ្នក អ្នកមានសិទ្ធិនិយាយប្រាប់ច្បាស់ៗថា អ្នកមិន អនុញ្ញាតឱ្យគាត់ចូលផ្ទះរបស់អ្នក ឬឆែកឆេរទ្រព្យសម្បត្តិរបស់អ្នកទេ។ ត្រូវ សួររកដីកាឆែកឆេរ និងចាប់ខ្លួន។

CITY OF LONG BEACH

City of Long Beach
ការណែនាំអំពីធនធានក្រោមច្បាប់ស្តីពីគុណតម្លៃនៃទីក្រុងឡុងប៊ិច (Long Beach Values Act)

ត្រៀមខ្លួនជាមុន

យកល្អគួរបង្កើតផែនការជាមួយគ្រួសារ មិត្តភក្តិ និងនិយោជករបស់អ្នក ក្នុងករណីមានភ្នាក់ងារអន្តោប្រវេសន៍ចូលទៅផ្ទះ ឬកន្លែងធ្វើការរបស់អ្នក។ សម្រេចចិត្តថានរណានឹងចាត់ចែងសំណុំរឿងរបស់អ្នក ហើយនរណានឹងផ្តល់ជំនួយ។ ត្រូវប្រាកដថាគ្រួសារ និងមិត្តភក្តិរបស់អ្នកដឹងថាត្រូវធ្វើអ្វី ប្រសិនបើអ្នកត្រូវបានឃុំខ្លួន។

ការពារខ្លួនអ្នកពីការបោកបន្លំ

ត្រូវប្រាកដថាមេធាវី ឬតំណាងផ្លូវច្បាប់ដែលអ្នកប្រើប្រាស់មានការទទួលស្គាល់ត្រឹមត្រូវ។ អ្នកអាចផ្ទៀងផ្ទាត់ចំណុចនេះដោយពិនិត្យមើលព័ត៌មានសម្គាល់ខ្លួនពួកគេតាមមុខងារស្វែងរកមេធាវីរបស់គណៈមេធាវីនៃរដ្ឋកាលីហ្វ័រញ៉ា។ ស្វែងរកជំនួយផ្លូវច្បាប់ពីមេធាវីមានអាជ្ញាបណ្ណ ឬអ្នកតំណាងដែលមានការទទួលស្គាល់ពីសហព័ន្ធប៉ុណ្ណោះ។ ប្រសិនបើអ្នកជឿថា អ្នកបានក្លាយជាជនរងគ្រោះនៃការក្លែងបន្លំ សូមទាក់ទងទៅការិយាល័យកិច្ចការអន្តោប្រវេសន៍នៃខោនធីឡូសអែនជេលេស (Los Angeles County Office of Immigrant Affairs) ដោយហៅទូរសព្ទទៅលេខ 1-800-593-8222 ឬចូលទៅកាន់គេហទំព័ររបស់ក្រសួងកិច្ចការអ្នកប្រើប្រាស់ និងអាជីវកម្មនៃខោនធីឡូសអែនជេលេស (LA County Department of Consumer and Business Affairs)។

ធនធានផ្លូវច្បាប់បន្ថែម

Centro CHA
Legal Aid Foundation of Los Angeles
L.A. Justice Fund
211 LA County
LA County Office of Immigrant Affairs
LA County Consumer and Business Affairs
Public Law Center
Asian Americans Advancing Justice SoCal
Bet Tzedek
Catholic Charities of Los Angeles
Central American Resource Center (CARECEN) of California
Children's Law Center of California
El Rescate
Immigration Center for Women and Children
International Institute of Los Angeles (IILA)
Legal Aid Foundation of Los Angeles
Los Angeles LGBT Center
Loyola Immigrant Justice Clinic

Peace Over Violence Legal Advocacy Project
Pomona Economic Opportunity Center (Pomona Day Laborer Center)
Access California Services
Community Legal Aid SoCal
Council of American-Islamic Relations (CAIR)
Public Law Center
Immigrant Defenders
Al Otro Lado

ធនធានផ្នែកសុខភាព

My Health LA
Medi-Cal For DACA Recipients
The Children's Clinic
Medi-Cal Outreach and Health Access Program
Women, Infants & Children Supplemental Nutrition Program
Clinica Monsenor Oscar A. Romero

ធនធានផ្នែកអប់រំ

Long Beach Unified Free English as a Second Language Class
Long Beach Public Library Career Online High School
Long Beach City College Resources for DACA Students
CSULB Dream Success Center
LBUSD Migrant Education

ធនធានផ្នែកការងារ និងអាជីវកម្ម

Korean Immigrant Workers Advocates of Southern California (KIWA)
Long Beach Workforce Innovation Network (LBWIN)
Filipino Migrant Center

សេវាជំនួយ

YMCA
Coalition for Humane Immigrant Rights (CHIRLA)
Korean Resource Center
The LGBTQ Center of Long Beach